អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១១

# <u>សេចក្តីប្រកាសព័ត៌មាន</u>

## បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងការបដិសេធសំណើសុំបំពេញកិច្ចស៊ើបសួរ ក្នុងសំណុំរឿង ០០៣

លោក Andrew Cayley ជាសហព្រះរាជអាជ្ញាអន្តរជាតិ សូមធ្វើសេចក្តីថ្លែងការណ៍នេះជាសាធារណៈ អនុលោមតាមវិធាន ២១ និងវិធាន ៥៤ នៃវិធានផ្ទៃក្នុង និងមាត្រា ១២(២) នៃកិច្ចព្រមព្រៀង អ.វ.ត.ក ដើម្បីធានាថា សាធារណជនទទួលបានព័ត៌មានទាន់ពេលវេលា អំពីកិច្ចដំណើរការនីតិវិធីកំពុងបន្តនៅ អ.វ.ត.ក នៅក្នុងសំណុំរឿង ០០៣ និងដោយធ្វើការពិចារណាទៅលើផលប្រយោជន៍របស់ជនរងគ្រោះ និងសាក្សី សិទ្ធិរបស់ជនសង្ស័យ និងលក្ខខណ្ឌតម្រូវនៃការស៊ើបអង្កេត។

កាលពីម្សិលមិញគឺនៅថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១១ អង្គបុរេជំនុំជម្រះនៃ អ.វ.ត.ក បានទទួលយកសំណៅកោសលុបជាសាធារណៈនៃបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងការបដិសេធរបស់សហចៅក្រមស៊ើបអង្កេតទៅលើ៖ ១) សំណើសុំពន្យារពេលវេលាសម្រាប់ដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី និង ២) សំណើចំនួនបីសុំបំពេញកិច្ចស៊ើបសួរក្នុងសំណុំរឿង ០០៣។ បណ្តឹងឧទ្ធរណ៍នេះស្នើសុំឱ្យអង្គបុរេជំនុំជម្រះប្រានចោលដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ដោយផ្អែកលើមូលដ្ឋានមួយចំនួន រួមទាំងការបកស្រាយច្បាប់មិនត្រឹមត្រូវ និងការរំលោភបំពានទៅលើកាតព្វកិច្ចផ្លូវច្បាប់របស់សហចៅក្រមស៊ើបអង្កេត ក្នុងការបើកកិច្ចស៊ើបសួរដែលពេញលេញ និងមិនលម្អៀង។ ដោយសារសហចៅក្រមស៊ើបអង្កេតបដិសេធសំណើសុំបំពេញកិច្ចស៊ើបសួរ របស់សហព្រះរាជអាជ្ញាអន្តរជាតិ ដោយផ្អែកលើមូលដ្ឋាននីតិវិធី បណ្តឹងឧទ្ធរណ៍ស្នើសុំអង្គបុរេជំនុំជម្រះធ្វើការណែនាំដល់សហចៅក្រមស៊ើបអង្កេត ឱ្យពិចារណាទៅលើសំណើទាំងនេះ ដោយផ្អែកលើអង្គសេចក្តី។

សំណៅកោសលុបនៃបណ្តឹងឧទ្ធរណ៍ អាចរកមើលបាននៅលើគេហទំព័របស់តុលាការ៖
https://www.eccc.gov.kh/en/document/court/international-co-prosecutors-appeal-against-decision-time-extension-request-and-inves.

---